# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**

**សីលធម៌ សច្ចធម៌ យុត្តិធម៌**


## សេចក្តីអំពាវនាវ

គណបក្ស សម រង្ស៊ី បាននិងកំពុងរៀបចំគំរោងដើម្បីសាងសង់ទីស្នាក់ការកណ្តាលគណបក្សជាអចិន្ត្រៃយ៍មួយ នៅរាជធានីភ្នំពេញ ដើម្បីសំរួលក្នុងការបំពេញការងារប្រចាំថ្ងៃ ។ ចាប់តាំងពីថ្ងៃបង្កើតគណបក្សជាតិខ្មែរ (គ.ជ.ខ.) ហើយក្រោយមកបានប្តូរឈ្មោះទៅជាគណបក្ស សម រង្ស៊ី យើងតែងតែជួលអគារសំរាប់ធ្វើជាទីស្នាក់ការកណ្តាលគណបក្ស ដោយសារខ្វះមធ្យោបាយក្នុងការសាងសង់ទីស្នាក់ការតាមតម្រូវការរបស់យើង ។

ចាប់តាំងពីឆ្នាំ១៩៩៥ គណបក្ស សម រង្ស៊ី មានការរីកចំរើនយ៉ាងឆាប់រហ័ស ហើយបានក្លាយទៅជាគណបក្សធំទី ២ នៅក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន ។ យើងទាំងអស់គ្នាមានគោលបំណងរួម គឺចង់ឲ្យគណបក្ស សម រង្ស៊ី ដឹកនាំប្រទេសជាតិ នាពេលអនាគតដ៏ខ្លីខាងមុខនេះ ។ ដើម្បីបំពេញសេចក្តីត្រូវការ យើងយល់ថាពេលវេលាបានមកដល់ហើយ ដើម្បីសាងសង់ទីស្នាក់ការកណ្តាលគណបក្សជាក់លាក់មួយនៅក្នុងរាជធានីភ្នំពេញ ដើម្បីបំពេញភារកិច្ច ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបចំពោះការព្រួយបារម្ភលើបញ្ហាសន្តិសុខ ។

ក្នុងហេតុផលនេះ ខ្ញុំសូមអំពាវនាវចំពោះសមាជិក-សមាជិកា និងអ្នកគាំទ្រគណបក្ស សម រង្ស៊ី ទាំងអស់ ដែលជាម្ចាស់ពិតប្រាកដរបស់គណបក្ស មេត្តាចូលរួមផ្តល់វិភាគទានសំរាប់សាងសង់ទីស្នាក់ការកណ្តាលគណបក្ស ដើម្បីយើងអាចបញ្ជាក់ពីដំណើរការវិវត្តដ៏សំខាន់របស់គណបក្ស សម រង្ស៊ី ។

គំរោងសាងសង់ទីស្នាក់ការកណ្តាលគណបក្ស ត្រូវចំណាយថវិកាប្រមាណ ២០០,០០០ ដុល្លារអាមេរិក ។ ប្រសិនបើសមាជិក-សមាជិកា អ្នកគាំទ្រគណបក្សម្នាក់ៗ ឬបណ្តាញរបស់គណបក្សទូទាំងពិភពលោកចូលរួមវិភាគទាន ទោះជាឥដ្ឋ ឬថ្មមួយដុំ ដើម្បីកសាងជញ្ជាំងមួយផ្នែក ឬបន្ទប់ការិយាល័យមួយ នោះអាចបង្ហាញឲ្យឃើញថា អ្វូរ អាចក្លាយជាទន្លេ ហើយគណបក្ស សម រង្ស៊ី នឹងមានទីស្នាក់ការកណ្តាលរបស់ខ្លួនដ៏សមរម្យនៅអំឡុងឆ្នាំ២០១០ ខាងមុខនេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមអំពាវនាវចំពោះសមាជិក-សមាជិកាគណបក្ស និងជនរួមជាតិទាំងអស់ សូមជួយផ្តល់វិភាគទានតាមសមានចិត្តសប្បុរស ទៅដល់តំណាងគណបក្ស សម រង្ស៊ី ដែលនៅជិតលោក-លោកស្រី ដើម្បីសំរេចគោលបំណងរួមរបស់យើងក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ ។

ក្នុងនាមអ្នកស្នេហាជាតិនៅកម្ពុជា ដែលមានក្តីសង្ឃឹមលើគណបក្ស សម រង្ស៊ី ខ្ញុំសូមសំដែងនូវអំណរគុណទុកជាមុន ចំពោះសមានចិត្តសប្បុរសរបស់សមាជិក-សមាជិកា និងអ្នកគាំទ្រគណបក្សទាំងអស់ ដែលបានចូលរួមផ្តល់វិភាគទានសំរាប់ការសាងសង់ទីស្នាក់ការកណ្តាលរបស់គណបក្ស សម រង្ស៊ី ។

សូមបងប្អូនសមាជិក-សមាជិកា និងអ្នកគាំទ្រគណបក្សទាំងអស់ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩* P.K

**ប្រធានគណបក្ស**

Sam Rainsy

**សម រង្ស៊ី**


**ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphq@online.com.kh, srpcabinet@online.com.kh, Website : samrainsyparty.org